ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ ០៣៣ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ ២០០៦

# ប្រកាសអន្តរក្រសួង
# ស្តីពី
# សោហ៊ុយលើសេវាសំណង់

❖❖❖❖❖❖

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរោបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

- បានឃើញអនុក្រឹត្យ លេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាស លេខ ៧៥ប្រក.ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាសក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់
- បានឃើញប្រកាស លេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំ លេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- យោងតាមការចាំបាច់លើការងារគ្រប់គ្រងវិស័យសំណង់ ។

## សំរេច

### ប្រការ ១ .-

ត្រូវបានបង្កើតសោហ៊ុយលើសេវាសំណង់ ក្នុងការពិនិត្យ និងសំរេចលើការសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ លើការចុះបញ្ជីប្រកបអាជីវកម្មសាងសង់ និងសិក្សាគំរោងប្លង់ ។

### ប្រការ ២ .-

សោហ៊ុយលើសេវាសំណង់មានចែងក្នុងប្រការ ១ ខាងលើ ត្រូវបានកំណត់ដូចតារាងខាងក្រោមនេះ ÷

**I- លិខិតអនុញ្ញាត ដែលជាសមត្ថកិច្ចរបស់សាលា ខេត្ត ក្រុង**

| ល.រ | រាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក. ពាក្យសុំ | ខ. តែម | គ. បង្កាន់ដៃទទួលពាក្យ | ឃ. ផ្ទៃក្រឡាគម្រោលសំណង់ | | | | | | | | |
| | | | | | ≤១០០ម² | ≤២០០ម² | ≤៣០០ម² | ≤៤០០ម² | ≤៥០០ម² | ≤១០០០ម² | ≤២០០០ម² | ≤៣០០០ម² | |
| | ក- លិខិតអនុញ្ញាតសាងសង់ | | | | | | | | | | | | |
| ១ | *សំណង់លំនៅឋាន* | | | | | | | | | | | | |
| | *១.១ ភូមិគ្រឹះ* | ២០០០ | ២០០០ | ៥០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ១៨០០០០ | ២០០០០០ | ២៤០០០០ | ២៨០០០០ | ៣២០០០០ | ក+ខ+គ-ឃ |
| | *១.២ ផ្ទះល្វែង* | ២០០០ | ២០០០ | ៥០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ២៨០០០០ | ដ |
| | *១.៣ ផ្ទះក្រោម ឈើលើ* | ២០០០ | ២០០០ | ៥០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ដ |
| ២ | *សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន* | ២០០០ | ២០០០ | ៥០០ | ១៤០០០០ | ១៦០០០០ | ១៨០០០០ | ២០០០០០ | ២២០០០០ | ២៦០០០០ | ៣០០០០០ | ៣៤០០០០ | ដ |

| ល.រ | រាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក. ពាក្យសុំ | ខ. តែម | គ. បង្កាន់ដៃទទួលពាក្យ | ឃ. ផ្ទៃក្រឡាកម្រាលសំណង់ | | | | | | | | |
| | | | | | ≤១០០ម² | ≤២០០ម² | ≤៣០០ម² | ≤៤០០ម² | ≤៥០០ម² | ≤១០០០ម² | ≤២០០០ម² | ≤៣០០០ម² | |
| ខ- លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | | | | | | | | | | | | |
| | ១.១ ភូមិគ្រឹះ | ២០០០ | ២០០០ | ៥០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ២៨០០០០ | ក+ខ+គ+ឃ |
| | ១.២ ផ្ទះល្វែង | ២០០០ | ២០០០ | ៥០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ដ |
| | ១.៣ ផ្ទះក្រោម ឈើលើ | ២០០០ | ២០០០ | ៥០០ | ២០០០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១៤០០០០ | ១៨០០០០ | ២២០០០០ | ដ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ១៨០០០០ | ២២០០០០ | ២៦០០០០ | ៣០០០០០ | ដ |
| គ- លិខិតអនុញ្ញាតបើកការដ្ឋាន | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | | | | | | | | | | | | |
| | ១.១ ភូមិគ្រឹះ | ២០០០ | ២០០០ | ៥០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ដ |
| | ១.២ ផ្ទះល្វែង | ២០០០ | ២០០០ | ៥០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៥០០០០ | ៧០០០០ | ៩០០០០ | ដ |
| | ១.៣ ផ្ទះក្រោម ឈើលើ | ២០០០ | ២០០០ | ៥០០ | ៥០០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៤៥០០០ | ៦៥០០០ | ៨៥០០០ | ដ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣០០០០ | ៣៥០០០ | ៤០០០០ | ៤៥០០០ | ៥០០០០ | ៧០០០០ | ៩០០០០ | ១១០០០០ | ដ |
| ឃ- លិខិតបិទការដ្ឋាន ឬ វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | | | | | | | | | | | | |
| | ១.១ ភូមិគ្រឹះ | ២០០០ | ២០០០ | ៥០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៤០០០០ | ៤៥០០០ | ៦៥០០០ | ៨៥០០០ | ១០៥០០០ | ដ |
| | ១.២ ផ្ទះល្វែង | ២០០០ | ២០០០ | ៥០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៥៥០០០ | ៧៥០០០ | ៩៥០០០ | ដ |
| | ១.៣ ផ្ទះក្រោម ឈើលើ | ២០០០ | ២០០០ | ៥០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៥០០០០ | ៧០០០០ | ៩០០០០ | ដ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣៥០០០ | ៤០០០០ | ៤៥០០០ | ៥០០០០ | ៥៥០០០ | ៧៥០០០ | ៩៥០០០ | ១១៥០០០ | ដ |

## II - លិខិតអនុញ្ញាត ដែលជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ល.រ | រាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក. ពាក្យសុំ | ខ. តែម | គ. បង្កាន់ដៃទទួលពាក្យ | ឃ. ផ្ទៃក្រឡាកម្រាលសំណង់ | | | | | | | | |
| | | | | | ≤៤០០០ម² | ≤៦០០០ម² | ≤១០០០០ម² | ≤២០០០០ម² | ≤៤០០០០ម² | ≤៦០០០០ម² | ≤១០០០០០ម² | >១០០០០០ម² | |
| ក- លិខិតអនុញ្ញាតសាងសង់ | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣៦០០០០ | ៤៤០០០០ | ៦០០០០០ | ៦៨០០០០ | ៧៦០០០០ | ៨៤០០០០ | ១០០០០០០ | ១៥០០០០០ | ក+ខ+គ+ឃ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣៨០០០០ | ៤៦០០០០ | ៦២០០០០ | ៧០០០០០ | ៧៨០០០០ | ៨៦០០០០ | ១០២០០០០ | ១៥២០០០០ | ដ |

| ល.រ | រាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក. ពាក្យសុំ | ខ. តែម | គ. បង្កាន់ដៃទទួលពាក្យ | ឃ. ផ្ទៃក្រឡាកម្រាលសំណង់ | | | | | | | | |
| | | | | | ≤៤០០០ម² | ≤៦០០០ម² | ≤១០០០០ម² | ≤២០០០០ម² | ≤៤០០០០ម² | ≤៦០០០០ម² | ≤១០០០០០ម² | >១០០០០០ម² | |
| | ខ- លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល | | | | | | | | | | | | |
| ១ | *សំណង់លំនៅឋាន* | ២០០០ | ២០០០ | ៥០០ | ៣២០០០០ | ៤០០០០០ | ៥៦០០០០ | ៦៤០០០០ | ៧២០០០០ | ៨០០០០០ | ៩៦០០០០ | ១៤៦០០០០ | ក+ខ+គ+ឃ |
| ២ | *សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន* | ២០០០ | ២០០០ | ៥០០ | ៣៤០០០០ | ៤២០០០០ | ៥៨០០០០ | ៦៦០០០០ | ៧៤០០០០ | ៨២០០០០ | ៩៨០០០០ | ១៤៨០០០០ | ដ |
| | គ- លិខិតអនុញ្ញាតបើកការដ្ឋាន | | | | | | | | | | | | |
| ១ | *សំណង់លំនៅឋាន* | ២០០០ | ២០០០ | ៥០០ | ១៤០០០០ | ២២០០០០ | ៣៨០០០០ | ៤៦០០០០ | ៥៤០០០០ | ៦២០០០០ | ៧៨០០០០ | ១២៨០០០០ | ដ |
| ២ | *សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន* | ២០០០ | ២០០០ | ៥០០ | ១៥០០០០ | ២៣០០០០ | ៣៩០០០០ | ៤៧០០០០ | ៥៥០០០០ | ៦៣០០០០ | ៧៩០០០០ | ១២៩០០០០ | ដ |
| | ឃ- លិខិតបិទការដ្ឋាន ឬ វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ | | | | | | | | | | | | |
| ១ | *សំណង់លំនៅឋាន* | ២០០០ | ២០០០ | ៥០០ | ១៤៥០០០ | ២២៥០០០ | ៣៨៥០០០ | ៤៦៥០០០ | ៥៤៥០០០ | ៦២៥០០០ | ៧៨៥០០០ | ១២៨៥០០០ | ដ |
| ២ | *សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន* | ២០០០ | ២០០០ | ៥០០ | ១៥៥០០០ | ២៣៥០០០ | ៣៩៥០០០ | ៤៧៥០០០ | ៥៥៥០០០ | ៦៣៥០០០ | ៧៩៥០០០ | ១២៩៥០០០ | ដ |

ផ្ទៃក្រឡាកម្រាលសំណង់ ដែលត្រូវយកសោហ៊ុយលើសេវាចំពោះការសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល គឺត្រូវកំណត់យកតែផ្ទៃក្រឡាកម្រាលសំណង់សាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ដោយមិនបូកបញ្ចូលនូវផ្ទៃក្រឡាកម្រាលសំណង់មានស្រាប់ ។

**III- ការចុះបញ្ជីប្រកបអាជីវកម្ម ដែលជាសមត្ថកិច្ចមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង**

| ល.រ | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រភេទ | ក. ពាក្យសុំ | ខ. តែមប្រិ | គ. បង្កាន់ដៃទទួលពាក្យ | ឃ. វិញ្ញាបនប័ត្រ | ង. សេវាប្រតិបត្តិ | ទឹកប្រាក់សរុប |
| | ក- ចុះបញ្ជីលើកដំបូង | | | | | | |
| ១ | *ក្រុមជាងសំណង់* | ២០០០ | ២០០០ | ៥០០ | ២០០០ | ៦០០០០ | ក+ខ+គ+ឃ+ង |
| | ខ- បន្តសុពលភាព | | | | | | |
| ២ | *ក្រុមជាងសំណង់* | ២០០០ | ២០០០ | ៥០០ | ២០០០ | ៤០០០០ | ដ |

IV- ការចុះបញ្ជីប្រកបអាជីវកម្ម ដែលជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ល.រ | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រភេទ | ក. ពាក្យសុំ | ខ. តែម | គ. បង្កាន់ដៃទទួលពាក្យ | ឃ. វិញ្ញាបនប័ត្រ | ង. សេវាប្រតិបត្តិតាមប្រភេទ ចំណាត់ថ្នាក់នីមួយៗ | ទឹកប្រាក់សរុប |
| ក- ចុះបញ្ជីលើកដំបូង | | | | | | | |
| ១ | ប្រភេទ ៣ (តូច) | ២០០០ | ២០០០ | ៥០០ | ២០០០ | ១០០០០០ | ក+ខ+គ+ឃ+ង |
| ២ | ប្រភេទ២ (មធ្យម) | ២០០០ | ២០០០ | ៥០០ | ២០០០ | ២០០០០០ | ដ |
| ៣ | ប្រភេទ១ (ធំ) | ២០០០ | ២០០០ | ៥០០ | ២០០០ | ៣០០០០០ | ដ |
| ខ- បន្តសុពលភាព | | | | | | | |
| ១ | ប្រភេទ ៣ (តូច) | ២០០០ | ២០០០ | ៥០០ | ២០០០ | ៨០០០០ | ដ |
| ២ | ប្រភេទ២ (មធ្យម) | ២០០០ | ២០០០ | ៥០០ | ២០០០ | ១៥០០០០ | ដ |
| ៣ | ប្រភេទ១ (ធំ) | ២០០០ | ២០០០ | ៥០០ | ២០០០ | ២០០០០០ | ដ |
| គ- ដំឡើងឋានៈប្រភេទ | | | | | | | |

| ល.រ | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រភេទ សុំដំឡើង | ក. ពាក្យសុំ | ខ. តែម | គ. បង្កាន់ដៃទទួលពាក្យ | ឃ. វិញ្ញាបនប័ត្រ | ង. សេវាប្រតិបត្តិតាមប្រភេទ ចំណាត់ថ្នាក់នីមួយៗ | ទឹកប្រាក់សរុប |
| ១ | ប្រភេទ៣ (តូច) -ប្រភេទ២ (មធ្យម) | ២០០០ | ២០០០ | ៥០០ | ២០០០ | ១៥០០០០ | ក+ខ+គ+ឃ+ង |
| ២ | ប្រភេទ២ (មធ្យម) -ប្រភេទ១ (ធំ) | ២០០០ | ២០០០ | ៥០០ | ២០០០ | ២៥០០០០ | ដ |

**ប្រការ ៣ ..**

ម្ចាស់សំណង់ត្រូវទទួលបន្ទុកបន្ថែមលើថ្លៃបង្គោល និងការដាំបង្គោល ។

ចំពោះសំណង់ដែលមានទីតាំងឆ្ងាយលើសពី ៥០គីឡូម៉ែត្រពីអង្គភាពជំនាញ ម្ចាស់សំណង់ត្រូវទទួលបន្ទុកបន្ថែមលើ ៖

១- សោហ៊ុយធ្វើដំណើរស្នាក់នៅ ហូបចុករបស់មន្ត្រីជំនាញ

២- ចំពោះតំបន់ដាច់ស្រយាល សោហ៊ុយលើសេវាសំណង់ត្រូវគិតបន្ថែម ២០% លើសោហ៊ុយសេវាសំណង់សរុប ។

**ប្រការ ៤ ._**

រាល់ទំរង់បែបបទ និងសំណុំឯកសារដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមនីតិវិធីនៃការសុំលិខិតអនុញ្ញាតជាធរមាន ។

**ប្រការ ៥ ._**

ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីសោហ៊ុយលើសេវាសំណង់ ត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យករចំណូលនៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ឬ ថ្នាក់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ៦ ._**

ការគ្រប់គ្រងចំណូលពីសោហ៊ុយលើសេវាសំណង់ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ។

**ប្រការ ៧ ._**

ចំណូលពីសោហ៊ុយលើសេវាសំណង់ត្រូវបង់ ១០០%ចូលថវិការដ្ឋ ដោយកត់ត្រាក្នុងជំពូក ២១ ប្រការ ០៣ កថាខណ្ឌ ៣០ ថវិកាខេត្ត ក្រុង និងថវិកាឃុំ សង្កាត់នៅរតនាគារជាតិ និងខេត្ត ក្រុង ។

**ប្រការ ៨ ._**

ចំណូលពីសោហ៊ុយលើសេវាសំណង់ ត្រូវបានកំណត់បែងចែកដូចខាងក្រោម ÷

ក-ចំណូលពីសោហ៊ុយលើសេវាផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ សំរាប់សមត្ថកិច្ចសាលាខេត្ត ក្រុង ត្រូវបានបែងចែកដូចតទៅ ÷

- ៣០% សំរាប់បង់ចូលថវិការដ្ឋ
- ៣០% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ
- ៣០% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា ខេត្ត ក្រុង ក្នុងនោះមាន ១០% ជាចំណែករបស់ស្រុក ខណ្ឌ
- ១០% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា របស់ឃុំ សង្កាត់ ។

ខ-ចំណូលពីសោហ៊ុយលើសេវាផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬ វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ សំរាប់សមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបែងចែកដូចតទៅ ÷

- ៣០% សំរាប់បង់ចូលថវិការដ្ឋ

- ៣៥% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ
- ២៥% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា ខេត្ត ក្រុង ក្នុងនោះមាន ៨% ជាចំណែករបស់ស្រុក ខណ្ឌ
- ១០% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា របស់ឃុំ សង្កាត់ ។

គ- ចំណូលពីសោហ៊ុយលើសេវាចុះបញ្ជីប្រកបអាជីវកម្ម សំរាប់សមត្ថកិច្ចមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ត្រូវបានបែងចែកដូចតទៅ ÷

- ៤០% សំរាប់បង់ចូលថវិការដ្ឋ
- ៣៥% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ
- ២៥% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា ខេត្ត ក្រុង ។

ឃ- ចំណូលពីសោហ៊ុយលើសេវាចុះបញ្ជីប្រកបអាជីវកម្ម សំរាប់សមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបែងចែកដូចតទៅ ÷

- ៣០% សំរាប់បង់ចូលថវិការដ្ឋ
- ៧០% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ ។

**ប្រការ ៩ ..**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ ត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុង១ត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសលាកប័ត្របង់ប្រាក់ ។

ផ្អែកលើការបូកសរុបស្ថានភាពបង់ចំណូលប្រចាំត្រីមាស អង្គភាពដែលមានចំណែកត្រូវលើកសំណើសុំចំណាយក្នុងរង្វង់ភាគរយ (%) នៃចំណូលរបស់ខ្លួន ដែលបានបង់ចូលថវិកាតាមបណ្តាថ្នាក់រៀង១ខ្លួន ទៅអង្គភាពហិរញ្ញវត្ថុ ដើម្បីពិនិត្យសំរេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួល តែត្រូវភ្ជាប់មកជាមួយនូវ ÷

- សលាកប័ត្របង់ប្រាក់ចំណូលពីសោហ៊ុយលើសេវាសំណង់

- របាយការណ៍ចំណាយនៃចំណែកភាគរយ (%) របស់ខ្លួន ដែលថវិការដ្ឋបានបើកផ្តល់លើកមុន ដោយមានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវ ។

នីតិវិធីនៃការបើក ផ្តល់ ចំណាយ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក ១០ ប្រការ ០២ កថាខណ្ឌ ០៣ វាក្យខណ្ឌ ០៧ ដែលមាននូវអាទិភាពក្នុងការបើកផ្តល់សាច់ប្រាក់ ។

**ប្រការ ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**ចំលងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ